ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រុមប្រឹក្សាអាជ្ញាកណ្តាល
THE ARBITRATION COUNCIL

លេខ និង ឈ្មោះសំណុំរឿង ៖ ០៣៣/១៩ - ជុន ស៊ីន ហ្ស៊ី យី ឯ.ក
កាលបរិច្ឆេទនៃសេចក្តីបង្គាប់ ៖ ថ្ងៃទី០៩ ខែឧសភា ឆ្នាំ២០១៩

# សេចក្តីបង្គាប់អាជ្ញាកណ្តាល

(ធ្វើឡើងស្របតាមមាត្រា ៣១៣ នៃច្បាប់ស្តីពីការងារ)

## សមាសភាពក្រុមអាជ្ញាកណ្តាល

អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីនិយោជក ៖ អ៊ុក រី
អាជ្ញាកណ្តាលជ្រើសរើសឡើងដោយភាគីកម្មករនិយោជិត ៖ អន ណន
ប្រធានក្រុមអាជ្ញាកណ្តាលជ្រើសរើសឡើងដោយអាជ្ញាកណ្តាលទាំងពីរខាងលើ ៖ គង់ ផល្លះ

## ភាគីនៃវិវាទ

**១- ភាគីនិយោជក**

ឈ្មោះ ៖ **ក្រុមហ៊ុន ជុន ស៊ីន ហ្ស៊ី យី ឯ.ក**
អាសយដ្ឋាន ៖ ភូមិត្រពាំងក្រសាំង ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល
ទូរស័ព្ទ ៖ ០១៥ ៥៦ ០០ ៨៨ ទូរសារ ៖ គ្មាន
តំណាងភាគីនិយោជកចូលរួមសវនាការ៖

១- លោកស្រី នុត សុវណ្ណារី ប្រធានរដ្ឋបាល
២- លោក តុប ស៊ីថា ប្រធានផ្នែកគ្រប់គ្រង

**២- ភាគីកម្មករនិយោជិត**

ឈ្មោះ ៖ **ភាគីតំណាងកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួម នៃក្រុមហ៊ុន ជុន ស៊ីន ហ្ស៊ី យី ឯ.ក**
អាសយដ្ឋាន ៖ ភូមិត្រពាំងក្រសាំង ឃុំបែកចាន ស្រុកអង្គស្នួល ខេត្តកណ្តាល
ទូរស័ព្ទ ៖ ០១០ ៥៣ ២៧ ២០ ទូរសារ ៖ គ្មាន
តំណាងភាគីកម្មករនិយោជិតចូលរួមសវនាការ៖

១- លោក តែប តុន ប្រធានសហព័ន្ធសហជីពអភិវឌ្ឍន៍កម្មករ
២- លោក នួន សុគុណ មន្ត្រីសហព័ន្ធសហជីពអភិវឌ្ឍន៍កម្មករ
៣- លោក សៅ សុជាតិ មន្ត្រីសហព័ន្ធសហជីពអភិវឌ្ឍន៍កម្មករ
៤- លោក វឿន សំនៀង កម្មករ
៥- លោក វឿន សារិន កម្មករ



ផ្ទះលេខ ៧២ ផ្លូវលេខ ៥៩២ (កែងផ្លូវលេខ ៣២៧) សង្កាត់បឹងកក់ ២ ខណ្ឌទួលគោក រាជធានីភ្នំពេញ ។ ទូរស័ព្ទ/ទូរសារ: ៨៥៥-២៣ ៨៨១ ៨២៤
No. 72, Street 592 (corner of St. 327), Sangkat Boeung Kak II, Khan Tuol Kork, Phnom Penh • Tel/Fax: 855-23 881 824
E-mail: secretariat@arbitrationcouncil.org • Website: www.arbitrationcouncil.org

៦- លោកស្រី ឌូ សុផា　　　　　កម្មករ

៧- លោក សូ វង្ស　　　　　　　កម្មករ

៨- លោកស្រី វុទ្ធ ម៉ារីណា　　　　កម្មករ

## បញ្ហាវិវាទ

(នៅក្នុងរបាយការណ៍ផ្សះផ្សាមិនសះជា)

- ស្នើឲ្យក្រុមហ៊ុនទទួលយកលោកស្រី ឌូ សុផា ជាតំណាងកម្មករចូលធ្វើការងារវិញជាធម្មតា ដោយគិតប្រាក់រំលឹក ចាប់តាំងពីថ្ងៃបញ្ឈប់ រហូតដល់ថ្ងៃចូលធ្វើការវិញ។ ករណីលោកស្រី ឌូ សុផា ត្រូវបានក្រុមហ៊ុនបញ្ចប់កិច្ចសន្យាការងារមានថិរវេលាកំណត់ តាំងពីថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៩ មក ហើយក្រុមហ៊ុនស្នើសុំដោះស្រាយវិវាទការងារបុគ្គលវិញ ក្រុមហ៊ុនសូមទូទាត់បញ្ចប់កិច្ចសន្យាការងារដែលនៅសេសសល់របស់សាមីខ្លួន ផ្អែកតាមច្បាប់ស្តីពីការងារ។

## អំណាចយុត្តាធិការរបស់ក្រុមប្រឹក្សាអាជ្ញាកណ្តាល

ក្រុមប្រឹក្សាអាជ្ញាកណ្តាលទទួលអំណាចក្នុងការចេញសេចក្តីបង្គាប់នេះ ដោយយោងតាមជំពូកទី១២ ផ្នែកទីពីរ (ខ) (មាត្រា ៣០៩ ដល់ ៣១៧) នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ប្រកាសស្តីពីក្រុមប្រឹក្សាអាជ្ញាកណ្តាល លេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ វិធាននៃនីតិវិធីក្រុមប្រឹក្សាអាជ្ញាកណ្តាល ដែលភ្ជាប់ជាឧបសម្ព័ន្ធ នៃប្រកាសលេខ ០៩៩ សកបយ ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ២០០៤ និងប្រកាសស្តីពីការតែងតាំងសមាជិកក្រុមប្រឹក្សាអាជ្ញាកណ្តាលលេខ ២២០ ក.ប/ប្រ.ក.វ.ក ចុះថ្ងៃទី២៣ ខែឧសភា ឆ្នាំ២០១៨ (អាណត្តិទី១៦)។

ការព្យាយាមផ្សះផ្សាវិវាទការងាររួម ដែលជាកម្មវត្ថុនៃសេចក្តីបង្គាប់នេះ ត្រូវបានធ្វើឡើងស្របតាមជំពូកទី១២ ផ្នែកទី២ (ក) នៃច្បាប់ស្តីពីការងារ។ ប៉ុន្តែ ការផ្សះផ្សានោះ ភាគីទាំងពីរមិនបានឯកភាពសះជានឹងគ្នាឡើយ ហើយរបាយការណ៍ស្តីអំពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ជុន ស៊ីន ហ្វី យី ឯ.ក លេខ ៥៩១/១៩ ក.ប/កណ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩។

## សវនាការ និង សង្ខេបនីតិវិធី

**ទីកន្លែងសវនាការ ៖** ក្រុមប្រឹក្សាអាជ្ញាកណ្តាល ភូមិគ្រឹះលេខ ៧២ ផ្លូវលេខ ៥៩២ កាច់ជ្រុងផ្លូវលេខ ៣២៧ (ទល់មុខវិទ្យាល័យឥន្ទ្រទេវី), សង្កាត់បឹងកក់ ២, ខណ្ឌទួលគោក, រាជធានីភ្នំពេញ ។

**កាលបរិច្ឆេទសវនាការ ៖** ថ្ងៃអង្គារ ៤រោច ខែចេត្រ ឆ្នាំកុរ ឯកស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី២៣ ខែមេសា ឆ្នាំ២០១៩ វេលាម៉ោង ១៤ និង ០០ នាទី រសៀល។

**បញ្ហានីតិវិធី ៖**

មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានទទួលពាក្យបណ្តឹងរបស់តំណាងប្រតិភូចរចានៃក្រុមហ៊ុន ជុន ស៊ីន ហ្វី យី ឯ.ក ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩ ស្តីពីការទាមទារសុំឲនិយោជកកែលំអលក្ខខណ្ឌការងារ ចំនួន ១២ ចំណុច។ បន្ទាប់ពីបានទទួលពាក្យបណ្តឹងនេះមក មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានចាត់មន្ត្រីជំនាញធ្វើការស៊ើបអង្កេត និងធ្វើការផ្សះផ្សាវិវាទ ចំនួន ១២ ចំណុចនេះ នៅថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩ ដោយមិនទទួលបានលទ្ធផលសះជានឹងគ្នា ចំនួន ១ ចំណុច។ ចំណុចមិនសះជាចំនួន ១ ចំណុចនេះ ត្រូវបានបញ្ជូនមកលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅថ្ងៃទី១០ ខែមេសា ឆ្នាំ

THE ARBITRATION COUNCIL

២០១៩ តាមរបាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ជុន ស៊ីន ហ្សី យី ឯ.ក លេខ ៥៩១/១៩ ក.ប/កណ ចុះថ្ងៃទី៩ ខែមេសា ឆ្នាំ២០១៩។

បន្ទាប់ពីបានទទួលសំណុំរឿងនេះ ក្រុមអាជ្ញាកណ្តាលត្រូវបានបង្កើតឡើង នៅថ្ងៃទី១១ ខែមេសា ឆ្នាំ ២០១៩។ លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល បានធ្វើការកោះអញ្ជើញភាគីនិយោជក និងភាគីកម្មករ និយោជិតមកសវនាការ និងធ្វើការផ្សះផ្សាលើករណីមិនសះជា ចំនួន ១ ចំណុចនេះ នៅថ្ងៃទី២៣ ខែមេសា ឆ្នាំ ២០១៩ វេលាម៉ោង ១៤ ៖ ០០ នាទី រសៀល។ ភាគីទាំងពីរ មានវត្តមាននៅក្នុងសវនាការ តាមការអញ្ជើញ របស់លេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្តាល។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានព្យាយាមសួររកនូវអង្គហេតុផ្សេងៗ ដែលទាក់ទងទៅនឹងចំណុចវិវាទនេះ និងបានធ្វើការផ្សះផ្សាលើចំណុចមិនសះជា ចំនួន ១ ចំណុចនេះបន្ថែមទៀត ដោយមិនទទួលបានលទ្ធផល សះជានឹងគ្នាទេ។ ដូចនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលនឹងធ្វើការពិចារណាលើចំណុចវិវាទដែលមិនសះជានឹងគ្នា ចំនួន ១ ចំណុចនេះ។

នៅក្នុងសំណុំរឿងនេះ ភាគីជ្រើសរើសយកសេចក្តីបង្គាប់មិនជាប់កាតព្វកិច្ច ។

នៅថ្ងៃសវនាការ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបានកំណត់ថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៩ ជាថ្ងៃចុងក្រោយ នៃការផ្តល់ភស្តុតាង និងថ្ងៃទី២ ខែឧសភា ឆ្នាំ២០១៩ ជាថ្ងៃចុងក្រោយនៃការជំទាស់ភស្តុតាង។

ភាគីទាំងពីរឯកភាពពន្យាកាលបរិច្ឆេទនៃការចេញសេចក្តីបង្គាប់អាជ្ញាកណ្តាលពីថ្ងៃទី៦ ខែឧសភា ឆ្នាំ ២០១៩ ទៅថ្ងៃទី៩ ខែឧសភា ឆ្នាំ២០១៩។

ដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណា និងដោះស្រាយលើចំណុចវិវាទខាងលើនេះ ដោយ ផ្អែកលើភស្តុតាង និងការរកឃើញនៃអង្គហេតុ ដូចខាងក្រោម ៖

**ភស្តុតាង**

សាក្សី និង អ្នកជំនាញក្រៅពីភាគី ៖ គ្មាន

**ឯកសារ ភស្តុតាង ដែលក្រុមអាជ្ញាកណ្តាលយកមកពិចារណាមាន**

**ក- ឯកសារបានទទួលពីភាគីនិយោជក ៖**

១- លិខិតផ្ទេរសិទ្ធិរបស់លោក Ly Chunlony ជានាយកក្រុមហ៊ុន ជុន ស៊ីន ហ្សី យី ឯ.ក ចុះថ្ងៃទី១០ ខែមេសា ឆ្នាំ២០១៩ គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសំណើសុំ ផ្ទេរសិទ្ធិជូន លោកស្រី នុត សុវណ្ណារី ជាប្រធានរដ្ឋបាល។

២- លិខិតផ្ទេរសិទ្ធិរបស់លោក Ly Chunlony ជានាយកក្រុមហ៊ុន ជុន ស៊ីន ហ្សី យី ឯ.ក ចុះថ្ងៃទី ២៣ ខែមេសា ឆ្នាំ២០១៩ គោរពជូន ប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពី សំណើសុំផ្ទេរសិទ្ធិជូនលោក គុប ស៊ីហា ជាប្រធានផ្នែកគ្រប់គ្រង។

៣- លិខិតចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៩ របស់នាយកក្រុមហ៊ុន ជុន ស៊ីន ហ្សី យី ឯ.ក គោរពជូន លោកប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល ស្តីពីសូមជូនដំណឹងបញ្ចប់ កិច្ចសន្យាការងារមានថិរវេលាកំណត់ចំពោះកម្មការិនីឈ្មោះ [illegible] សុផា មានតួនាទីជាប្រធានក្រុមធំ និងអត្តលេខ CX ១០៨។

៤- លិខិតជូនដំណឹងស្តីពីការបញ្ចប់កិច្ចសន្យាការងារកម្មការិនីឈ្មោះ ឌូ សុផា ចុះថ្ងៃទី០១ ខែមីនា ឆ្នាំ២០១៩។

៥- លិខិតបញ្ចប់ពីការងាររបស់កម្មការិនីឈ្មោះ ឌូ សុផា។

៦- តារាងប្រាក់បៀវត្សប្រចាំខែកុម្ភៈ និងខែមីនា ឆ្នាំ២០១៩។

៧- កំណត់ហេតុស្តីពីករណីផ្តល់ព័ត៌មានពាក់ព័ន្ធពាក្យបណ្តឹងរបស់បងប្អូនកម្មករដែលមានចំណុចទាមទារចំនួន១២ ចំណុច ចុះថ្ងៃទី១៣ ខែមីនា ឆ្នាំ២០១៩។

៨- សេចក្តីជូនដំណឹងជម្រាបជូនកម្មករ-កម្មការិនី ស្តីពីលោកនាយកក្រុមហ៊ុន ជុន ស៊ីន ហ្ស៊ី យី ឯ.ក បានឯកភាពផ្តល់ជូននូវលក្ខខណ្ឌការងារមួយចំនួន ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០១៩។

៩- លិខិតចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩ របស់កម្មករ កម្មការិនី នៃក្រុមហ៊ុន ជុន ស៊ីន ហ្ស៊ី យី ឯ.ក គោរពជូន លោកនាយកក្រុមហ៊ុន ជុន ស៊ីន ហ្ស៊ី យី ឯ.ក ស្តីពីសំណើសូមក្រុមហ៊ុនកែប្រែលក្ខខណ្ឌការងារចំនួន ១២ចំណុច និងឯកភាពគ្នាទាំងស្រុងចាត់តាំងតំណាង ៦ រូប ១.អ្នកស្រី ឌូ សុផា ២.លោក សូ វង្ស ៣.អ្នកស្រី វុទ្ធ ម៉ារីណា ៤. លោក រឿន សារិន ៥.អ្នកស្រី គុន ស្រ៊ុន ៦.លោក ជីប គង្គា ធ្វើជាប្រតិភូចរចារ ចុះថ្ងៃទី០៧ ខែមីនា ឆ្នាំ២០១៩។

១០- របៀបគិតប្រាក់ឈ្នួល និងអត្ថប្រយោជន៍។

១១- សេចក្តីជូនដំណឹងពាក់ព័ន្ធនឹងការឈប់សម្រាកលំហែមាតុភាព (សំរាលកូន)។

១២- លិខិតចុះថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩ របស់នាយកក្រុមហ៊ុន ជុន ស៊ីន ហ្ស៊ី យី ឯក គោរពជូនលោកប្រធានលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល ស្តីពីសារណាសង្ខេបនៃវិវាទការងារការពារសំណុំរឿងលេខ ០៣៣/១៩។

១៣- លក្ខន្តិកៈក្រុមហ៊ុន ជុន ស៊ីន ហ្ស៊ី យី ឯក បានតម្កល់ទុកលេខ ០០០២៩៥៣៦ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧ នៅនាយកដ្ឋានចុះបញ្ជីពាណិជ្ជកម្ម នៃក្រសួងពាណិជ្ជកម្ម។

១៤- បទបញ្ជាផ្ទៃក្នុងរបស់ក្រុមហ៊ុន ជុន ស៊ីន ហ្ស៊ី យី ឯក បានចុះបញ្ជិកាលេខ លេខ ១០១៥/១៨ ក.ប.វ ចុះថ្ងៃទី២៣ ខែកក្កដា ឆ្នាំ២០១៨ ដោយប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល។

១៥- វិញ្ញាបនបត្របញ្ជាក់ការចុះឈ្មោះក្នុងបញ្ជីពាណិជ្ជកម្ម ក្រុមហ៊ុន ជុន ស៊ីន ហ្ស៊ី យី ឯ.ក លេខ MOC-៩១៤១៧០៨៧ ពណ.ចបព ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧។

១៦- ឯកសារជាភាសាបរទេស។

**ខ- ឯកសារបានទទួលពីភាគីកម្មករនិយោជិត ៖ គ្មាន**

**គ- ឯកសារបានទទួលពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

១- របាយការណ៍ស្តីពីការដោះស្រាយវិវាទការងាររួមនៅក្រុមហ៊ុន ជុន ស៊ីន ហ្ស៊ី យី ឯ.ក លេខ ៥៩១/១៩ ក.ប/កណ ចុះថ្ងៃទី០៩ ខែមេសា ឆ្នាំ២០១៩។

THE ARBITRATION COUNCIL

២- កំណត់ហេតុនៃការផ្សះផ្សាវិវាទការងាររួមនៅក្រុមហ៊ុន ជុន ស៊ីន ហ្ស៊ី យី ឯ.ក ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩។

៣- លិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិតក្នុងការដោះស្រាយវិវាទការងាររួមនៃក្រុមហ៊ុន ជុន ស៊ីន ហ្ស៊ី យី ឯ.ក លេខ ០០៩/១៩ ចុះថ្ងៃទី០៨ ខែមេសា ឆ្នាំ២០១៩ របស់មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល។

ឃ- ឯកសារបានទទួលពីលេខាធិការដ្ឋានក្រុមប្រឹក្សាអាជ្ញាកណ្តាល

១- លិខិតអញ្ជើញភាគីនិយោជកចូលរួមសវនាការ លេខ ២១៣ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ០៨កើត ខែចេត្រ ឆ្នាំច សំរិទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩។

២- លិខិតអញ្ជើញភាគីកម្មករនិយោជិតចូលរួមសវនាការ លេខ ២១៤ កប/អក/វក/លកអ. ចុះថ្ងៃសុក្រ ០៨កើត ខែចេត្រ ឆ្នាំច សំរិទ្ធិស័ក ព.ស ២៥៦២ ត្រូវនឹងថ្ងៃទី១២ ខែមេសា ឆ្នាំ២០១៩។

## អង្គហេតុ

- ក្រោយពីបានពិនិត្យរបាយការណ៍នៃការផ្សះផ្សាវិវាទការងាររួម
- ក្រោយពីបានស្តាប់អំណះអំណាងរបស់តំណាងភាគីកម្មករនិយោជិត និងនិយោជក
- ក្រោយពីបានពិនិត្យឯកសារបន្ថែម

ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ៖

- ក្រុមហ៊ុន ជុន ស៊ីន ហ្ស៊ី យី ឯ.ក (តទៅនេះហៅថា ក្រុមហ៊ុន ជុន ស៊ីន ហ្ស៊ី យី) ដែលមានសកម្មភាពចម្បងក្នុងការកាត់ដេរសម្លៀកបំពាក់ និងបានទទួលវិញ្ញាបនបត្របញ្ជាក់ការចុះបញ្ជីពាណិជ្ជកម្មក្រោមលេខ ០០០២៩៥៣៦ ចុះថ្ងៃទី២២ ខែវិច្ឆិកា ឆ្នាំ២០១៧។ បច្ចុប្បន្ន ក្រុមហ៊ុននេះ មានជួលកម្មករនិយោជិតចំនួនជា ២៧០ នាក់។
- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្តកណ្តាល បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិត ក្នុងការដោះស្រាយវិវាទការងាររួម លេខ ០០៩/១៩ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ២០១៩ ដែលមានកម្មករនិយោជិត ចំនួន ៦ នាក់ គឺ ១. ឌូ សុផា ២. សូ វង្ស ៣. វុធ ម៉ារីណា ៤.រឿន សំនៀង ៥.ងួន ស្រីកី និង៦.រឿន សារិន ជាតំណាងកម្មករនិយោជិតនៃក្រុមហ៊ុន ជុន ស៊ីន ហ្ស៊ី យី នៅក្នុងការដោះស្រាយវិវាទការងាររួម។
- នៅថ្ងៃសវនាការអាជ្ញាកណ្តាល គឺមានវត្តមានរបស់តំណាងកម្មករនិយោជិតទាំង ៥ នាក់ គឺ១. រឿន សំនៀង ២. រឿន សារិន ៣. ឌូ សុផា ៤. សូ វង្ស និង៥. វុទ្ធ ម៉ារីណា (វុធ ម៉ារីណា) ដែលមានឈ្មោះនៅក្នុងលិខិតបញ្ជាក់អ្នកតំណាងខាងលើ។
- មិនមានអង្គហេតុបញ្ជាក់ថា នៅក្នុងក្រុមហ៊ុននេះ មានសហជីពដែលមានភាពជាតំណាងបំផុតទេ។

**ចំណុចវិវាទ ៖ កម្មករនិយោជិតស្នើសុំឲក្រុមហ៊ុនទទួលយកលោកស្រី ឌូ សុផា ជាតំណាងកម្មករចូលធ្វើការងារវិញជាធម្មតា ដោយគិតប្រាក់បៀវត្សចាប់តាំងពីថ្ងៃបញ្ឈប់ រហូតដល់ថ្ងៃចូលធ្វើការវិញ**

- ភាគីទាំងពីរឯកភាពថា កម្មករនិយោជិត ឌូ សុផា ចូលធ្វើការដំបូងនៅថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០១៨ មានតួនាទីជាប្រធានផ្នែកដេរ និងជាប្រតិភូបុគ្គលិកពេញសិទ្ធិនៅក្នុងអាណត្តិ ដោយបានចុះកិច្ចសន្យា

ការងារដែលមានកំណត់ថិរវេលាចំនួន ៣ ខែ ដោយទទួលបានប្រាក់ឈ្នួលគោលចំនួន ៣៥០ ដុល្លារ ប្រាក់រង្វាន់ការងារទៀងទាត់ចំនួន ១៥ ដុល្លារ ប្រាក់ថ្លៃធ្វើដំណើរ និងស្នាក់នៅចំនួន ៧ ដុល្លារ និង ប្រាក់រង្វាន់អតីតភាពការងារចំនួន ២ ដុល្លារ ក្នុងមួយខែ។

- ភាគីកម្មករនិយោជិតបញ្ជាក់ថា កម្មករនិយោជិត ឌូ សុផា មិនធ្លាប់បានចុះកិច្ចសន្យាការងារទៀតទេ ក្រោយពីបានចុះកិច្ចសន្យាការងារដែលមានកំណត់ថិរវេលាចំនួន ៣ ខែ នៅថ្ងៃចូលធ្វើការដំបូងរួចមក។
- ករណីនេះ ភាគីនិយោជកបញ្ជាក់ថា កិច្ចសន្យាការងាររបស់កម្មករនិយោជិត ឌូ សុផា មានធ្វើជាបន្ត បន្ទាប់ដោយមានចុះហត្ថលេខាដោយថៅកែក្រុមហ៊ុន ប៉ុន្តែ មិនបានយកកិច្ចសន្យានេះទៅឲកម្មករ និយោជិតចុះហត្ថលេខាទេ ហើយនៅពេលដល់កាលកំណត់នៃកិច្ចសន្យាការងាររបស់គាត់ម្តងៗ និយោជកតែងតែទូទាត់ប្រាក់បំណាច់ ៥ ភាគរយ និងប្រាក់ជួសការឈប់សម្រាកប្រចាំឆ្នាំដែលនៅ សល់ ដល់កម្មករនិយោជិតជានិច្ច។
- ភាគីនិយោជកបញ្ជាក់បន្តថា កិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ៣ ខែ ចុងក្រោយ របស់កម្មករ និយោជិត ឌូ សុផា ត្រូវដល់កាលកំណត់នៅថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩ ហើយនិយោជកសម្រេច បញ្ចប់កិច្ចសន្យាការងាររបស់គាត់នៅថ្ងៃទី១ ខែមីនា ឆ្នាំ២០១៩ ដោយទូទាត់ប្រាក់ឈ្នួល និងប្រាក់ បំណាច់ផ្សេងៗរហូតដល់កាលកំណត់នៃកិច្ចសន្យាការងាររបស់គាត់។ ករណីនេះ សាម៉ីខ្លួនពុំទាន់មក ទទួលនូវការទូទាត់នៅឡើយទេ។
- ភាគីកម្មករនិយោជិតបញ្ជាក់ការទាមទារ ឲនិយោជកទទួលយកកម្មករនិយោជិត ឌូ សុផា ចូលធ្វើ ការងារវិញ។
- ភាគីកម្មករនិយោជិតបញ្ជាក់មូលហេតុនៃការទាមទារថា កម្មករនិយោជិត ឌូ សុផា ជាប្រតិភូបុគ្គលិក ហើយនិយោជកបញ្ឈប់ការងាររបស់គាត់ ដោយគាត់គ្មានប្រព្រឹត្តិកំហុស។
- ភាគីនិយោជកបញ្ជាក់ថា មិនអាចទទួលយកកម្មករនិយោជិត ឌូ សុផា ឲចូលធ្វើការងារវិញទេ និង យល់ព្រមទូទាត់ប្រាក់បំណាច់ស្របតាមច្បាប់ស្តីពីការងារ ដោយមូលហេតុ កម្មករនិយោជិតរូបនេះ បានប្រព្រឹត្តកំហុសច្រើនដង ការគ្រប់គ្រងសង្វាក់ផលិតកម្មមិនបានល្អ អវត្តមានពុំមានច្បាប់ច្រើនដង និងមិនស្តាប់តាមការណែនាំរបស់អ្នកគ្រប់គ្រង។ ករណីនេះ និយោជកបានជូនដំណឹងស្តីពីការបញ្ចប់ កិច្ចសន្យាការងារមានថិរវេលាកំណត់កម្មករនិយោជិត ឌូ សុផា ទៅមន្ទីរការងារខេត្តកណ្តាល តាមរយៈ លិខិតចុះនៅថ្ងៃទី១ ខែមីនា ឆ្នាំ២០១៩។

## **ហេតុផលនៃសេចក្តីសម្រេច ៖**

មុននឹងពិចារណាលើចំណុចទាមទារខាងក្រោមនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលពិចារណាអំពីដើម បណ្តឹងនៅក្នុងសំណុំរឿងនេះ ដូចខាងក្រោម ៖

កថាខណ្ឌទី១ មាត្រា ៥៤ នៃច្បាប់ស្តីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ ចែងថា ៖ *"ភាព ជាតំណាងបំផុតនៃសហជីពត្រូវបានទទួលស្គាល់នៅក្នុងក្របខ័ណ្ឌនៃសហគ្រាស ឬគ្រឹះស្ថាន។ សម្រាប់គោល បំណងនៃការចរចាអនុសញ្ញារួម ឬដោះស្រាយវិវាទរួមដោយផ្ទាល់ គឺសហជីពដែលមានភាពជាតំណាងបំផុតទទួល បានសិទ្ធិផ្តាច់មុខ។"*។

យោងតាមខ្លឹមសារនៃកថាខណ្ឌទី១ មាត្រា ៥៤ នៃច្បាប់ស្តីពីសហជីពខាងលើនេះ ក្រុមប្រឹក្សាអាជ្ញា- កណ្តាលយល់ថា មានតែសហជីពដែលមានភាពជាតំណាងបំផុតប៉ុណ្ណោះ ដែលមានសិទ្ធិផ្តាច់មុខនៅក្នុងការ

ចចោបង្កើតអនុសញ្ញារួម និងដោះស្រាយវិវាទការងាររួមនៅក្នុងសហគ្រាស ឬគ្រឹះស្ថានរបស់ខ្លួន។ សិទ្ធិផ្តាច់មុខក្នុងការដោះស្រាយវិវាទការងាររួមនេះ សំដៅលើសិទ្ធិក្នុងការនាំយកវិវាទ និងធ្វើជាតំណាងឲកម្មករនិយោជិតនៅគ្រប់នីតិវិធីដោះស្រាយវិវាទការងាររួម ដោយរួមបញ្ចូលទាំងនីតិវិធីដោះស្រាយវិវាទនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ។ *(សូមមើលបន្ថែមសេចក្តីបង្គាប់អាជ្ញាកណ្តាល លេខ ១៨០/១៦-ស៊ីម៉ង់ត៍ កម្ពុជា ចក្រីទីង និងលេខ ១៧១/១៦-ដេវើលីន ខូអិលធីឌី )*

នៅក្នុងសំណុំរឿងនេះ ពុំមានអង្គហេតុដែលបញ្ជាក់ថា នៅក្នុងក្រុមហ៊ុន ជុន ស៊ីន ហ្វ៊ី យី មានសហជីពដែលមានភាពជាតំណាងបំផុតទេ។

ប្រការ ១៦ នៃប្រកាសលេខ ៣០៣ ក.ប/ប្រ.ក.គ.ប.ក ស្តីពីភាពជាតំណាងបំផុតនៃសហជីព និងបែបបទ និងនីតិវិធីដើម្បីទទួលបានភាពជាតំណាងបំផុត ចុះថ្ងៃទី២ ខែកក្កដា ឆ្នាំ២០១៨ ចែងថា ៖ *"ក្នុងករណីសហគ្រាស គ្រឹះស្ថានដែលពុំទាន់មានសហជីព ឬពុំទាន់មានសហជីពដែលមានភាពជាតំណាងបំផុត ការដោះស្រាយវិវាទការងាររួម ត្រូវដោះស្រាយដោយអ្នកតំណាងកម្មករនិយោជិត។"* ។

លើសពីនេះ ប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ស្តីពីការធ្វើប្រតិភូកម្មមុខងារក្នុងការធ្វើបណ្តឹងអំពីវិវាទការងាររួម និងចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចចោ ចុះថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ចែងថា ៖ *"ត្រូវបានធ្វើប្រតិភូកម្មជូនដល់ប្រធាននាយកដ្ឋានវិវាទការងារ និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត នូវមុខងារ ដូចខាងក្រោម ៖*

[...]

*- ចេញលិខិតទទួលស្គាល់ប្រតិភូក្រុមប្រឹក្សាចចោ សម្រាប់ដោះស្រាយវិវាទការងាររួម។"*។

យោងតាមប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ថា នាយកដ្ឋានវិវាទការងារ និងប្រធានមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត មានមុខងារក្នុងការទទួលស្គាល់កម្មករនិយោជិតឲធ្វើជាតំណាងរបស់ភាគីកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទការងាររួម។ ដូច្នេះ កម្មករនិយោជិតដែលត្រូវបានទទួលស្គាល់ដោយនាយកដ្ឋានវិវាទការងារ ឬប្រធានមន្ទីរការងារ និងបណ្តុះបណ្តាល-វិជ្ជាជីវៈ ខេត្ត មានសិទ្ធិស្របច្បាប់ក្នុងការតំណាងឲភាគីកម្មករនិយោជិត ដើម្បីដោះស្រាយវិវាទការងាររួម ដោយរួមទាំងនៅដំណាក់កាលដោះស្រាយវិវាទការងារនៅក្រុមប្រឹក្សាអាជ្ញាកណ្តាលផងដែរ នៅពេលមិនទាន់មានវត្តមានរបស់សហជីពមានភាពតំណាងបំផុត។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ២២៣/១៦-យូនីកតា ថេកណេឡជី (ខេមបូឌា), លេខ ២២៤/១៦-កាស៊ីណូកោះមាស និង សណ្ឋាគារ, លេខ ០០៨/១៧-ថប រើលដ៍ ហ្គាមិន (ខេមបូឌា) អិលធីឌី និងលេខ ២៣៧/១៦-ហ្សិណា-ដាយឌុង (ខេមបូឌា) អេឡិចត្រូនិច)*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងនេះ ក៏យល់ស្របទៅនឹងការបកស្រាយរបស់ក្រុមប្រឹក្សា-អាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។

នៅក្នុងសំណុំរឿងនេះ មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ខេត្តកណ្តាល បានចេញលិខិតបញ្ជាក់អ្នកតំណាងភាគីកម្មករនិយោជិត ក្នុងការដោះស្រាយវិវាទការងាររួម លេខ ០០៩/១៩ ចុះថ្ងៃទី៨ ខែមេសា ឆ្នាំ ២០១៩ ដែលមានកម្មករនិយោជិត ចំនួន ៦ នាក់ គឺ ១. ឌូ សុផា ២. សូ វង្ស និង៣. វុធ ម៉ារីណា ៤.រឿន សំនៀង ៥.ងួន ស្រីភី និង៦.រឿន សារិន ជាតំណាងកម្មករនិយោជិតនៃក្រុមហ៊ុន ជុន ស៊ីន ហ្វ៊ី យី នៅក្នុងការដោះស្រាយវិវាទការងាររួម។ នៅថ្ងៃសវនាការអាជ្ញាកណ្តាល គឺមានវត្តមានរបស់តំណាងកម្មករនិយោជិតទាំង ៥ នាក់ គឺ១. រឿន សំនៀង ២. រឿន សារិន ៣. ឌូ សុផា ៤. សូ វង្ស និង៥. ទូ ម៉ារីណា (វុធ ម៉ារីណា) ដែលមានឈ្មោះនៅក្នុងលិខិតបញ្ជាក់អ្នកតំណាងខាងលើ។

ហេតុនេះ យោងតាមការបកស្រាយខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិតទាំង ៥ នាក់ ខាងលើ មានសិទ្ធិធ្វើជាតំណាងកម្មករនិយោជិតដែលជាដើមបណ្តឹងនៅក្នុងសំណុំរឿងនេះ ស្របតាមប្រការ១ នៃប្រកាសលេខ ៣៦២ ក.ប/ប្រ.ក ខាងលើ។

**ចំណុចវិវាទ ៖ ភាគីកម្មករនិយោជិតទាមទារឲនិយោជកទទួលយកកម្មករនិយោជិត ឌូ សុផា ចូលធ្វើការងារវិញ**

**ករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលធ្វើការពិចារណាថា តើកម្មករនិយោជិត ឌូ សុផា មានកិច្ចសន្យាការងារជាប្រភេទអ្វីជាមួយនឹងនិយោជក?**

មាត្រា ៦៧ ត្រង់ចំណុចទី ៨ នៃច្បាប់ស្តីពីការងារឆ្នាំ១៩៩៧ ចែងថា៖ *"នៅពេលណាកិច្ចសន្យាដែលធ្វើឡើងដោយមានកំណត់ថិរវេលាពិតប្រាកដតិចជាង ឬស្មើនឹងពីរឆ្នាំ ត្រូវបន្តដោយស្ងៀមស្ងាត់នៅពេលផុតកំណត់នោះ កិច្ចសន្យាត្រូវចាត់ទុកជាកិច្ចសន្យាគ្មានកំណត់ថិរវេលាពិតប្រាកដ។"*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងលេខ ២៧១/១៣-ឌី&អិល ហេតុផលនៃចំណុចវិវាទទី១ ក្រុមប្រឹក្សាអាជ្ញាកណ្តាល បានបកស្រាយថា ៖ *"ពាក្យថា "បន្តដោយស្ងៀមស្ងាត់នៅពេលផុតកំណត់" មានន័យថា មកដល់ពេលផុតកំណត់នៃកិច្ចសន្យាដែលមានកំណត់ ថិរវេលាដំបូង មិនមានភាគីណាមួយនៃកិច្ចសន្យា បានបង្ហាញឆន្ទៈក្នុងការបន្ត ឬមិនបន្តឡើងវិញនៃកិច្ចសន្យានោះទេ ហើយនៅក្រោយពេលផុតកំណត់នៃកិច្ចសន្យាដំបូងនេះ ទំនាក់ទំនងការងាររវាងកម្មករនិយោជិត ត្រូវបានបន្តទៅដោយស្ងៀមស្ងាត់។ ពោលគឺ កម្មករនិយោជិតនៅតែបន្តធ្វើការជម្មតាឲនិយោជក ហើយនិយោជកនៅតែផ្តល់នូវប្រាក់ឈ្នួល និងលក្ខខណ្ឌការងារផ្សេងៗ ដូចនៅក្នុងទំនាក់ទំនងការងារនៃកិច្ចសន្យាការងារដំបូងដែរ។ "*។

ក្រុមប្រឹក្សាអាជ្ញាកណ្តាលនៅក្នុងសំណុំរឿង ២៧១/១៣-ឌី&អិល ខាងលើ បានបកស្រាយចំណុចទី៨ នៃមាត្រា ៦៧ នៃច្បាប់ស្តីពីការងារថា ៖ *"នៅពេលណាដែលកិច្ចសន្យាដែលមានកំណត់ថិរវេលាមានថិរវេលាតិចជាង ឬស្មើនឹងពីរឆ្នាំ បានផុតកំណត់រួចហើយ ប៉ុន្តែ មកដល់ពេលផុតកំណត់នៃកិច្ចសន្យាការងារដែលមានកំណត់ថិរវេលានោះ មិនមានភាគីណាមួយនៃកិច្ចសន្យា បានបង្ហាញឆន្ទៈក្នុងការបន្ត ឬមិនបន្តនៃកិច្ចសន្យានោះទេ ហើយជាលទ្ធផល ទំនាក់ទំនងការងាររវាងកម្មករនិយោជិត និងនិយោជកនៅតែបានបន្តទៅជាជម្មតាដោយស្ងៀមស្ងាត់ នៅក្រោយពេលផុតកំណត់នៃកិច្ចសន្យានោះ ទំនាក់ទំនងការងាររវាងនិយោជក និងកម្មករនិយោជិត នៅក្រោយពេលផុតកំណត់នៃកិច្ចសន្យាដំបូងនឹងត្រូវបានបន្តដោយស្ងៀមស្ងាត់ និងត្រូវចាត់ទុកថា ស្ថិតនៅក្រោមប្រភេទកិច្ចសន្យាការងារដែលមានថិរវេលាមិនកំណត់។*

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនខាងលើដែរ។ យោងតាមអង្គហេតុខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលរកឃើញថា ក្រៅពីកិច្ចសន្យាការងារដែលមានកំណត់ថិរវេលាចំនួន ៣ ខែ ដែលនិយោជកបានធ្វើជាមួយនឹងកម្មករនិយោជិត ឌូ សុផា នៅពេលចូលធ្វើការងារដំបូងរួចមក និយោជកមិនបានធ្វើកិច្ចសន្យាការងារជាលាយលក្ខណ៍អក្សរជាមួយនឹងកម្មករនិយោជិត ឌូ សុផា ទៀតទេ ហើយកម្មករនិយោជិតនៅបន្តធ្វើការងារដោយស្ងៀមស្ងាត់នៅក្នុងក្រុមហ៊ុនដូចដើម។ ករណីនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កម្មករនិយោជិត ឌូ សុផា មានកិច្ចសន្យាការងារមានថិរវេលាមិនកំណត់។

លើសពីនេះ មាត្រា ៦៧ ចំណុចទី៧ នៃច្បាប់ស្តីពីការងារដដែល ចែងថា៖ *"កិច្ចសន្យាការងារមានកំណត់ថិរវេលាពិតប្រាកដ ត្រូវធ្វើជាលាយលក្ខណ៍អក្សរ។ បើមិនធ្វើជាលាយលក្ខណ៍អក្សរទេ កិច្ចសន្យានេះក្លាយជាកិច្ចសន្យាគ្មានថិរវេលាពិតប្រាកដ។"*

ក្រុមប្រឹក្សាអាជ្ញាកណ្តាល នៅក្នុងសំណុំរឿងលេខ ១៨៣/១៤-សាន់ ឡុង ត្រង់ហេតុផលនៃចំណុចវិវាទទី១ បានបកស្រាយថា ៖ *"...លក្ខខណ្ឌចាំបាច់របស់កិច្ចសន្យាការងារដែលមានកំណត់ថិរវេលាពិតប្រាកដ គឺត្រូវធ្វើជាលាយលក្ខណ៍អក្សរ។ កិច្ចសន្យាការងារទាំងឡាយណា ដែលមិនបានធ្វើជាលាយលក្ខណ៍អក្សរនោះទេ កិច្ចសន្យានោះ នឹងក្លាយជាកិច្ចសន្យាការងារមានថិរវេលាមិនកំណត់។"។ (សូមមើលបន្ថែមសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ២៧១/១៣-ឌីអ៊ិល ខាងលើ ហេតុផលចំណុចវិវាទទី៨, លេខ ០៩២/១៥-ស៊ីអាន ហ្វាអាង ហ្គាមេន ហ្វេកធើរី ខូអិលធីឌី ហេតុផលនៃចំណុចវិវាទបន្ថែម, លេខ ១៥០/១៦-ស្កាយណាយ អ៊ិនធើណេសិនណល ខូ អិលធីឌី ហេតុផលនៃចំណុចវិវាទទី១ និងលេខ ១៧៩/១៦-ដាលី ហ្គាម៉ិន អ៊ិនធើណេសិនណល (ខេមបូឌា) លីមីតធីត ហេតុផលចំណុចវិវាទទី១)*

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលក៏យល់ស្របនឹងការបកស្រាយរបស់ក្រុមអាជ្ញាកណ្តាលនៅក្នុងសំណុំរឿងមុនខាងលើដែរ។ តាមខ្លឹមសារនៃមាត្រា ៦៧ ចំណុចទី៧ នៃច្បាប់ស្តីពីការងារខាងលើនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា កិច្ចសន្យាការងារដែលមានកំណត់ថិរវេលា ត្រូវគោរពតាមលក្ខខណ្ឌទម្រង់ជាចាំបាច់ ពោលគឺ កិច្ចសន្យាការងារនេះ ត្រូវតែធ្វើជាលាយលក្ខណ៍អក្សរ។

សរុបសេចក្តីមក យោងតាមការបកស្រាយចំណុចទី៧ និងទី៨ នៃ មាត្រា ៦៧ នៃច្បាប់ស្តីពីការងារ និងសេចក្តីបង្គាប់ក្រុមប្រឹក្សាអាជ្ញាកណ្តាលខាងលើ កិច្ចសន្យាការងាររបស់កម្មករនិយោជិត ឌូ សុផា គឺជាកិច្ចសន្យាការងារមានថិរវេលាមិនកំណត់។

**ហេតុនេះ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបន្តពិចារណាថា តើនិយោជកបញ្ឈប់កម្មករនិយោជិត ឌូ សុផា ដែលជាប្រតិភូបុគ្គលិក ត្រឹមត្រូវតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់ស្តីពីការងារដែរ ឬទេ?**

ក្នុងករណីនេះ កម្មករនិយោជិត ឌូ សុផា គឺជាប្រតិភូបុគ្គលិកពេញសិទ្ធិ នៅក្នុងអាណត្តិ ហើយនិយោជកសម្រេចបញ្ចប់កិច្ចសន្យាការងាររបស់គាត់នៅថ្ងៃទី១ ខែមីនា ឆ្នាំ២០១៩ ដោយមិនមានលិខិតអនុញ្ញាតពីអធិការការងារ។

មាត្រា ៤៣ នៃច្បាប់ស្តីពីសហជីព ចុះថ្ងៃទី១៧ ខែឧសភា ឆ្នាំ២០១៦ បានចែងថា *"រាល់ការបញ្ឈប់ប្រតិភូបុគ្គលិក ឬរាល់ការបញ្ឈប់បេក្ខជនណាម្នាក់ពីការងាររបស់ខ្លួន អាចធ្វើទៅបានលុះត្រាតែមានការយល់ព្រមពីអធិការការងារ។ [...]*

*អធិការការងារដែលបានទទួលពាក្យបណ្តឹងសុំបញ្ឈប់កម្មករនិយោជិត ដូចមានចែងក្នុងមាត្រានេះ ត្រូវផ្តល់សេចក្តីសម្រេចរបស់ខ្លួនដល់និយោជក និងដល់កម្មករនិយោជិតដែលត្រូវបញ្ឈប់ក្នុងរយៈពេល ១ (មួយ)ខែយ៉ាងយូរ ក្រោយទទួលពាក្យបណ្តឹង។...។"*

ផ្អែកលើខ្លឹមសារនៃមាត្រា ៤៣ នៃច្បាប់ស្តីពីសហជីពខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្តាលយល់ឃើញថា រាល់ការបញ្ឈប់កម្មករនិយោជិត ដែលជាប្រតិភូបុគ្គលិក ឬកម្មករនិយោជិតណាម្នាក់ដែលត្រូវទទួលបានការការពារពីការបញ្ឈប់ស្របតាមមាត្រានេះ និយោជកត្រូវទទួលបានការអនុញ្ញាតពីអធិការការងារជាមុនសិន មុននឹងធ្វើការបញ្ឈប់រូបគាត់ពីការងារ។

នៅក្នុងសេចក្តីបង្គាប់អាជ្ញាកណ្តាលមុនៗ ក្រុមប្រឹក្សាអាជ្ញាកណ្តាលបង្គាប់ឲនិយោជកទទួលយកកម្មករនិយោជិតជាប្រតិភូបុគ្គលិក ដែលទទួលបានការការពារពិសេសពីការបញ្ឈប់ពីការងារឲចូលធ្វើការវិញ នៅពេលនិយោជកធ្វើការបញ្ឈប់ពួកគាត់ពីការងារ មិនស្របតាមនីតិវិធីច្បាប់ ដោយមិនបានសុំការអនុញ្ញាតពីអធិការការងារ។ *(សូមមើលសេចក្តីបង្គាប់អាជ្ញាកណ្តាលលេខ ១៧៩/១៦-ដាលី ហ្គាម៉ិន អ៊ិនធើណេសិនណល (ខេមបូ*

*ឌ) លីមីតធីត ហេតុផលនៃចំណុចវិវាទទី១, លេខ ០០៥/១៧-អ៊ី ហ្វ៊ុល ហ្គាមេន (ខេមបូឌា) អិលធីឌី ហេតុផលនៃចំណុចវិវាទទី៣)*

នៅក្នុងសំណុំរឿងនេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលក៏យល់ស្របនឹងការសម្រេចរបស់ក្រុមប្រឹក្សាអាជ្ញាកណ្ដាល នៅក្នុងសំណុំរឿងមុនៗ ខាងលើដែរ។ តាមរយៈអង្គហេតុ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលរកឃើញថា កម្មករនិយោជិត ឌូ សុផា ជាប្រតិភូបុគ្គលិកពេញសិទ្ធិនៅក្នុងអាណត្តិ ដែលត្រូវទទួលបានការការពារពិសេសពីការបញ្ឈប់ពីការងារ។ ករណីនេះ និយោជកបានជូនដំណឹងទៅមន្ទីរការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ ខេត្តកណ្ដាល ប៉ុន្តែ អធិការការងារមិនទាន់បានចេញលិខិតអនុញ្ញាតឲ្យនិយោជកធ្វើការបញ្ឈប់ការងាររបស់កម្មករនិយោជិត ឌូ សុផា នៅឡើយទេ។ ហេតុដូច្នេះ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលយល់ឃើញថា និយោជកបញ្ឈប់កម្មករនិយោជិត ឌូ សុផា ដែលជាប្រតិភូបុគ្គលិក មិនត្រឹមត្រូវតាមនីតិវិធីដែលមានចែងនៅក្នុងច្បាប់ស្ដីពីសហជីពនោះទេ។

ជាមួយគ្នានេះ ប្រការ៣៤ នៃប្រកាស ០៩៩ ស្ដីពីក្រុមប្រឹក្សាអាជ្ញាកណ្ដាល ចុះថ្ងៃទី២១ ខែមេសា ឆ្នាំ ២០០៤ ចែងថា ៖ *"...ក្រុមប្រឹក្សាអាជ្ញាកណ្ដាលមានសិទ្ធិ និងអំណាចក្នុងការសម្រេចចោទភាគីវិវាទផ្ដល់នូវសំណងជម្ងឺបុរណី ឬសំណងខូចខាត ដែលមានលក្ខណៈត្រឹមត្រូវ និងយុត្តិធម៌ ដោយរួមទាំងការ ក.បញ្ជាឲទទួលយកកម្មករ និយោជិត ដែលបានបណ្ដេញចេញ ឲចូលមកធ្វើការវិញ...ឃ. បញ្ជាឲបញ្ឈប់ជាបន្ទាន់នូវរាល់ការប្រព្រឹត្តទាំងឡាយណា ដែលមិនស្របច្បាប់..."*។

សរុបមក ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេច បង្គាប់ឲនិយោជកទទួលយកកម្មករនិយោជិត ឌូ សុផា ឲចូលធ្វើការងារវិញ។

យោងតាមការបង្ហាញភស្តុតាង អង្គហេតុ អង្គច្បាប់ និងហេតុផល ដូចបានបញ្ជាក់ខាងលើ ក្រុមប្រឹក្សាអាជ្ញាកណ្ដាលសម្រេចចេញសេចក្ដីបង្គាប់ ដូចតទៅ ៖

## សម្រេច និង បង្គាប់

**ចំណុចវិវាទ ៖**

- បង្គាប់ឲនិយោជកទទួលយកកម្មករនិយោជិត ឌូ សុផា ឲចូលធ្វើការងារវិញ។

**ប្រភេទនៃសេចក្ដីបង្គាប់ ៖ សេចក្ដីបង្គាប់មិនជាប់កាតព្វកិច្ច**

សេចក្ដីបង្គាប់នេះ នឹងក្លាយជាស្ថាពរ បន្ទាប់ពីថ្ងៃជូនដំណឹងអំពីសេចក្ដីបង្គាប់ ចំនួន ០៨ ថ្ងៃ បើសិនជាមិន មានភាគីណាមួយដាក់ពាក្យជំទាស់ជាលាយលក្ខណ៍អក្សរទៅរដ្ឋមន្ត្រីក្រសួងការងារ និងបណ្ដុះបណ្ដាលវិជ្ជាជីវៈ តាម រយៈលេខាធិការដ្ឋាននៃក្រុមប្រឹក្សាអាជ្ញាកណ្ដាល ក្នុងរយៈពេលនេះទេ។

**ហត្ថលេខារបស់សមាជិកក្រុមអាជ្ញាកណ្ដាល**

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីនិយោជក ៖**

ឈ្មោះ ៖ **អ៊ុក រី**

ហត្ថលេខា ៖ ------------------------------

**អាជ្ញាកណ្ដាលជ្រើសរើសដោយភាគីកម្មករនិយោជិត ៖**

ឈ្មោះ ៖ **អន ណាន**

ហត្ថលេខា ៖------------------------------

THE ARBITRATION COUNCIL

ប្រធានក្រុមអាជ្ញាកណ្តាល ៖

ឈ្មោះ ៖ **គង់ ផល្លះ**

ហត្ថលេខា ៖ ---------------

THE ARBITRATION COUNCIL